# ល្បងសិក្សាសត្រាច្បាប់ចិន

ដោយ

សាស្ត្រាចារ្យ ឃីងហុកឌី

## សត្រាច្បាប់ចិន សរសេរតាមអក្ខរាវិរុទ្ធទំនើប

« នេះសត្រាច្បាប់ចិន ។

| | | |
|---|---|---|
| ១- កូនអើយចូលស្តាប់ | ទៀរនឹងប្រាយប្រាប់ | ចូលបាស្តាប់ហោង |
| កូនយកចានទាប | យកចានកន្ទោង | ដួសបបរហោង |
| នឹងរកជះពឹង[1]ៗ | | |
| ២- ជះពឹងរួចហើយ | អ្នកមាសទៀរ[2]ហើយ | រួសរាល់វិលវឹង |
| យកភ្លើងដុតផ្ទាំង | ដុះហុន( ?)បើនឹង | បាយទៀរវិលវឹង |
| ឆាប់ឡើងវៃៗ ។ | | |
| ៣- ថាបើបាយឆៅ | កុំជះពឹងទៅ | ថាឈឺបាំងសែ[3] |
| ហើមពោះត្រអុល | ខ្យល់(-)ខ្វាំងក្រៃ[4] | ផោមព្រួតបាំងក្ហួយ[5] |
| ស្អុយអស់អ្នកផង។ | | |
| ៤- ដើរត្រង់ណាផ្លូវ | កូនកុំដើរទៅ | បាំងសែឡើយហោង |
| គេជេរផ្តាសា | លន់ៗកង់ៗ | កើតពាក្យសៅហ្មង |

[1] ជះពឹង(ចិន) : ស៊ីបាយ ;  ជះមួយ(ចិន) : ស៊ីបបរ ។

[2] ទៀរ (ចិន ) : មា (ប្តីម្តាយមីងខាងម្តាយ),  ក្នុងន័យទូលាយ សម្គាល់ ឪពុក,បិតា ។

[3] បាំងសែ=ដុះអាចម៍. សែ=អាចម៍, បាំង=អង្គុយ, ទំ។

[4] ឃ្លានេះខ្វះមួយព្យាង្គ។

[5] បាំងក្ហួយ (ចិន ) : ផោម ។

| | | |
|---|---|---|
| ជ្សិតតែបាំងសែ ។ | | |
| ៥- បើកូនឈឺនោម | ឈឺពោះឈឺផោម | ក្រោកលើងឲ្យវៃ |
| កុំសម្ងំនៅ | ជាលេចបាំងសែ | គេខ្លើមពេកក្រៃ |
| អួចយះខាកថ្ងើយ ។ | | |
| ៦- បើឈឺក្បាលសែ[6] | តឹងពោះតឹងផ្ទៃ | កូនកុំតោះតើយ |
| ទៅរកចន្ទោះ | បាំងសែឲ្យហើយ | នៅថ្ងៃព្រងើយ |
| វាលេចបណ្ដូលសែ ។ | | |
| ៧- កូនស្ងួនសង្វារ | ស្រេចស្រួលត្រអាល | រត់លេងសប្បាយបៃ |
| ទៀរនឹងតាក់ផ្សារ | ធ្វើការអ្វីៗ | ចិញ្ចឹមជីវី |
| ជីវិតសព្វថ្ងៃ ។ | | |
| ៨- កូនអើយចូរស្ដាប់ | ទៀរទូន្មានគាប់ | ចង់អស់សេចក្ដី |
| ទាំងជុះទាំងនោម | ទាំងផោមបាំងកួយ | ជះពឹងជះជួយ[7] |
| ទៀរអ្នកប្រដៅ ។ | | |
| ៩- កូនក្មេងសេចក្ដី | ពុំទាន់ដឹងអ្វី | ភាសាពាក់ជ្រៅ |
| ស្ដាប់ទៀរថ្ងាថ្លៃង | ទូន្មានបុត្រពៅ | នេះច្បាប់ចិនចៅ |
| មកនៅស្រុកខ្មែរ ។ | | |
| ១០- ខ្លួនបាធំហើយ | អ្នកមាសទៀរអើយ | កុំធ្វើតែលវៃល |
| ដូចកាលនៅក្មេង | ជុះដាក់កន្ទេល | មាសធំឡើងក្រៃល |
| ដឹងក្ដីហើយណា ។ | | |
| ១១- ផៅសេ( ?)[8]ចូលស្ដាប់ | អស់ភាសាសព្វ | បិតំបិតា |
| បើនឹងរកធី | ចេញជួញក្ដីណា | កូនមាសពុំងា |

[6] ក្បាលអាចម៍

[7] ជះជួយ(ចិន) : ផឹកទឹកៗ ជះជីវ (ចិន) = ផឹកស្រា

[8] កូនអាពុក(?)

| | | |
|---|---|---|
| ស្តាប់ទៀរប្រដៅ ។ | | |
| ១២- កុំកូនឃុន[9]ពេក | សម្ងំដេកផ្អែក | លក់សំកុកនៅ |
| ដោះឡើងពីព្រឹក | រឭកណាចៅ | កុំដំងើចនៅ |
| ក្រោកឡើងម្ទឹម្ទា ។ | | |
| ១៣- កំលេងបៀប៉ោ | បាញ់កាស[10]បោះធួរ | អ្នកណានាងណា |
| កុំជក់អាភៀន | កុំរៀនផឹកស្រា | វាអបក[11] |
| មុខម្តាយអាពុក។ | | |
| ១៤- រៀនគិតរៀនជួញ | ចំណេញជំនួញ | វានឹងបានសុខ |
| ទិញចូលលក់ចេញ | ចំណេញទៅមុខ | បើថោកកូនទុក |
| បានថ្លៃលក់ទៅ ។ | | |
| ១៥- កុំកូនបុត្រភ្ញា | បង្អង់ឡើយណា | វានឹងសាសៅ |
| អសារគំនិត | កូនគិតឲ្យជ្រៅ | កូនកុំដើរទៅ |
| បោះកៅ[12]វេះវេ ។ | | |
| ១៦- មិនបានយល់កៅ | បូកឆ្នូតខោអាវ | នូវលានជៀរទៀរ ( ?) |
| នៅតែពងពីរ | ស្ថិតស្ថេរក្រោមមេ | គេទារមិនល្ហែ |
| តេងតាងអាត្មា ។ | | |

[9] ខ្ជិល ( ?)

[10] របិយវត្ថុសម្រាប់ចាយមានសណ្ឋានមូលប្រហោងកណ្តាល៤ជ្រុងធ្វើដោយស្ពាន់, ទង់ដែង, សាំង្កសី, មកពីស្រុកចិន ឬ ស្រុកអណ្ណាម, សព្វថ្ងៃក្នុងដែនកម្ពុជាលែងប្រើរូបិយវត្ថុនេះតាំងពីមានសេន។ វចនានុក្រមខ្មែរ, ទំព័រ៣៧។

[11] ក្នុងសត្រាចារថា « អព្វបក » គឺ មកពី បាលី សំស្ក្រឹត « **អបក** » មានន័យថា « ឈ្នះ, មិនចាញ់« តែខ្មែរប្រជាប្រិយឱ្យនិយមន័យផ្ទុយទៅវិញ បានសេចក្តីថា »ចាញ់, អាប់ឱន « ទៅវិញ។ ទីនេះមានន័យ អាប់ឱន មុខមាត់អាពុកម្តាយ។ល។

[12] កៅ(ចិន) : ៩ គឺឈ្មោះល្បែងចិន ដែលមានរូប៩ ហើយនិងមានរូប៣ទៀតគឺ កម្ញោះ (Valet) ក្រមុំ (Reine)និងស្តេច(អុង, Roi) ហើយធំជាងគេគឺ អាត(As) ។

| | | |
|---|---|---|
| ១៧- ដូចឃ្មុំឥតមេ | នៅតែខ្លួនទេ | សំបុកនៅវាល |
| គេពុំទុកឡើយ | គ្រែងខ្វចអសារ | គេចាប់សង្ក្រារ |
| ចាប់កូនប្រពន្ធ ។ | | |
| ១៨- មាសប្រាក់ពុំគង់ | ដោះចង់ដោះទៃ[13] | បង់អស់ទុនរុន |
| ថែមទាំងដើមទុន | វារីងច្រើនស៊ុន | ស្រេកកៅម្ដងទៀត |
| -------- ។ | | |
| ១៩- បើកូនកល្យាណ | កូនខំរុករៀន | គុង្គានលេងទៀត |
| វារីងតែលង់ | សូន្យសុងបង់សៀត | ស្រែកកៅម្ដងទៀត |
| តសសែ( ?)ក្សយមនី( ?) ។ | | |
| ២០- បើកូនមិនលះ | ប៉ោបៀស្រឡះ | ធ្លាក់ជាខ្ញុំគេ |
| គេប្រើសព្វថ្ងៃ | ឥតបីមានល្ហែ | បទតែអាបៀ |
| ប៉ោឲ្យបង់កេរ ។ | | |
| ២១- អាប់មុខអាប់មាត់ | សន្តានញាតិរតន៍ | សម្បត្តិពុំសួរ |
| បទតែអាប៉ោ | បង់កាស[14]បង់កេរ | ញាតិសាច់ចិនខ្មែរ |
| គេពុំរាប់មុខ ។ | | |
| ២២- កូនរៀនជួញវិញ | ជំនួញចំណេញ | នោះមហាបានសុខ |
| សារពើទំនិញ | ក្រវាញកុយក្ដុក | បើល្អអាក្រក់ |
| សុខតាមថ្ងៃវា ។ | | |
| ២៣- នោះវាប្រសើដ្ឋ | ផ្សេរផ្សំបណ្ដើរ | បណ្ដាំផ្សំគ្នា |

[13] ចង់រាង់វែងធ្វើដោយសំពត់មានមាត់ពីរសម្រាប់ច្រកអ្វីៗហើយចងមាត់ភ្ជាប់គ្នាស្រាយបាន។ វចនានុក្រមខ្មែរ, ទំព័រ ៤៥៤។

[14] រូបិយវត្ថុសម្រាប់ចាយមានសណ្ឋានមូលប្រហោងកណ្ដាល៤ជ្រុងធ្វើដោយស្ពាន់, ទង់ដែង, សាំង្កសី, មកពីស្រុកចិន ឬ ស្រុកអណ្ណាម, សព្វថ្ងៃក្នុងដែនកម្ពុជាលែងប្រើរូបិយវត្ថុនេះតាំងពីមានសេន។ វចនានុក្រមខ្មែរ, ទំព័រ៣៧។

| | | |
|---|---|---|
| សម្បត្តិសម្បូរ | ឥស្សូរសក្តា | ចិនខ្មែរចាមជ្វា |
| មូលមកសព្វថ្ងៃ ។ | | |
| ២៤- បើមានគេមក | អ្នកមាសអេរក | យកហិបម្ហូស្វា |
| ទោះបីចិនខ្មែរ | បារាំងលន្ទា[15] | ហៅគេធីស្វា |
| លៃជះលៅហៀក[16] | | |
| ២៥- គេឡើងមកដល់ | ធ្វើចិត្តឲ្យស្គាល់ | ស្រដីខ្សិបខ្សៀវ |
| កុំពាក្យបោកបោះ | ខ្នុរខ្នាស់កញ្ច្រៀវ | ស្រដីនឹងក្មៀវ |
| ពាក្យឲ្យចរចា ។ | | |
| ២៦- គេដើរមកសួរ | មករកទិញដូរ | អ្វីៗក្តីណា |
| ពុំលក់ពុំឲ្យ | ធ្វើចិត្តឲ្យជា | កុំកួនពំផា |
| ស្រដីបោកបោះ ។ | | |
| ២៧- គេនឹងរៀងចាល | នឹងកូនសង្សារ | ពាក្យរឹងសុរោះ[17] |
| គេនឹងរុញរា | ពាក្យថាឥតមោះ | វានឹងសូន្យសោះ |
| អសារទាមទេរ ។ | | |
| ២៨- ឥតគេស្រណោះ | ឥតគេអាឡោះ | អាល័យស្នាលស្នេហ៍ |
| ស្និទ្ធស្នាលមេត្រី | ១នៃឥតឯ | ណានិងត្រូវគេ |
| តូច១ឥតសុខ ។ | | |
| ២៩- បៀបោនោះនៃ | ចំណេញមួយថ្ងៃ | ១ពាន់សែនទុក្ខ |
| ពុំដែលនឹងបាន | សម្រាន្តសាន្តសុខ | ទុកកេរទៅមុខ |
| ឲ្យកូនប្រពន្ធ ។ | | |
| ៣០- រឺឯបៀប៉ោ | ១ស្ទឹងចូលមក៍ | ទុកស្មើភ្លើងស្កន |

[15] ជនជាតិ ហល់ឡង់ (Hollandais).

[16] ជះលៅហៀក(ចិន) : ស៊ីម្ហូ ; ( លៅ : ម្ហូ ; ហៀក : ស៊ិក) ។

[17] ក្លាយមកពីពាក្យអសុរោះ គឺមកពីបាលី អសុរ => អសុរោ => អសុរោះ

| | | |
|---|---|---|
| ចូលឆេះដល់ដាល | ពេលពាលជីពជន្ម | រលាយបាត់ធន |
| នូវផេះចង្ក្រាន ។ | | |
| ៣១- គ្មានគេនឹងមើល | មកមុខ( ?)ផ្ទះដាន | មានតែមាន់ទា |
| ផ្តែផ្កាពាសពាន | ផ្តែវារៀបចាន | ផ្ទាំងបាយសម្ងំ |
| ---------- [18] | | |
| ៣២- ពាក្យទៀរសេចគ្រេច | ទូន្មានសម្រេច | ច្បាប់ពីចិនមក |
| ឲ្យគិតឲ្យយល់ | យោបល់រិះរេ | ច្បាប់នេះកម្រ |
| ស្រុកខ្មែរនេះគ្មាន។ | | |
| ៣៣- មាសទៀរអើយចាំ | ពាក្យពេជចន៍បណ្តាំ | ចាំណាអ្នកណា |
| អ្នកមាសកល្យាណ | អីល្បែងបៀបោ | កាសធួរប៉ុន្មាន |
| ចាំទុកក្នុងប្រាណ | កុំភ្លេចឡើយនៃ ។[19] | |
| ៣៤- មាសទៀរ[20]អើយពៅ | ថាបើកូនចៅ | មានខ្ញុំប្រុសស្រី |
| ឲ្យគន់មើលចិត្ត | គំនិតវានៃ | ខ្ញុំណាគាប់ចៃ |
| ដឹងអស់ដឹងគង់ ។ | | |
| ៣៥- ឲ្យវាដាក់ទុក | ឲ្យធីឲ្យបុក | ឲ្យមើលក្រីក្រ |
| ចៃធីចៃធួន(?)ស្តាន | ខាតបាត់កុំយក៍ | វាដឹងក្រីក្រ |
| ដឹងអស់ដឹងគង់ ។ | | |
| ៣៦- ចិញ្ចឹមជ្រូកទា | អាសី[21]នោះណា | រ័ក្សាក្រោលទ្រុង |
| មើលឲ្យចំណី | កុំចោលបោះបង់ | មើលក្រោលមើលទ្រុង |
| រ័ក្សាសព្វថ្ងៃ ។ | | |

[18] ខ្វះកំណាព្យមួយឃ្លា ។

[19] វគ្គនេះលើស១ ឃ្លា ។

[20] សរសេរ « ទារ » យើងកែជា « ទៀរ » វិញ ដើម្បីឱ្យមានឯកភាព ។

[21] អាសី ប្រហែលពាក្យ ឫស្សី ( ?) ដែលគេយកធ្វើទ្រុង ឬ ក្រោលមាន់ទា ។ល។

| | | |
|---|---|---|
| ៣៧- កលមួយសោតណា | ចិញ្ចឹមខ្លែធ្លា | កៅជៀវ[22] ប្រក្រតី |
| ឆ្មាតែងសុកម | ផ្គួលសួស្តី | កៅដេកនៅដី |
| តែងចាំធនធាន ។ | | |
| ៣៨- ក្រែងមានមនុស្សម្នា | ចោរកាចឫស្សា | វាព្រុសកង់សៀន[23] |
| កូននឹងបានដឹង | ដំណឹងដោយដាន | ចោរចូលពុំបាន |
| ញញើតថយទៅ ។ | | |
| ៣៩- មួយសោតកាលបើ | ទ្រព្យធនសារពើ | ទោះបីក្នុងក្រៅ |
| កូនរើសទុកដាក់ | រៀបដោយលំនៅ | ផ្តូផ្តាប់ណាចៅ |
| រៀបទុកឲ្យហោរ[24] ។ | | |
| ៤០- ឆ្នាំងបាយសម្ល | ទុកដាក់ឲ្យហោរ[25] | ដោយលំនៅវា |
| ហុងជ្រូកទាស្ងោរ | គ្របព្យួរឲ្យជា | ប្រយ័ត្នខ្លែធ្លា |
| ពានពាំជះហុង ។ | | |
| ៤១- ទៀរនឹងឧបមា | ប្រដូចគង្គា | ជ្រោថ្វាឧដុង្គ |
| ត្រីតែងពឹងពាក់ | សម្នាក់នៅក្នុង | ជ្បិតមានអន្ទុង |
| ត្រជាក់សប្បាយ ។ | | |
| ៤២- ទឹកវាក់សោតក្តៅ | ត្រីពឹងតែងនៅ | ក្រហល់ក្រហាយ |
| ស្អុះចេញរចល់ | ទៅទីស្ថានឆ្ងាយ | បឹងសោនៅអាយ |
| ទឹកស្ងាត់សូន្យសុង ។ | | |
| ៤៣- កុំធ្វើចិត្តក្តៅ | ដេរពោលកូនចៅ | វាយប្រពន្ធកូន |

[22] កៅ(ចិន) : ខ្លែ ; ជៀវ(ចិន) : ឆ្មា ។ មានន័យថា « ខ្លែធ្លា » ផ្ទួននឹងពាក្យខ្មែរខាងមុខ ។

[23] ឮសូរខ្លាំង( ?)

[24] ហោរនេះជាពាក្យចិន មានន័យថា « ល្អ » ។

[25] ហោរ (ចិន) : ល្អ មានរបៀបរៀបរយ ។

| | | |
|---|---|---|
| វាយខ្ញុំកំដរ | វាយរត់ប្រពូន | ខឹងដេរផ្ទួនៗ |
| លេនបួរស្វាន្ទោះ( ?) ។ | | |
| ៤៤- ធ្វើការប៉ុន្មាន | មិញករ(?)ពុំក្សាន្ត | ស្រូវធីត្រគោះ |
| វាខឹងរត់ចេញ | ដូចនៃត្រីនោះ | អស់ឥតសូន្យសោះ |
| គឺមោះសុងសូន្យ ។ | | |
| ៤៥- ទឹកជ្រោថ្វារង | កូនយកចិត្តចង | ចាំទុកក្នុងប្រាណា |
| ពាក្យទៀរប្រដៅ | កូនពៅមាសស្ងួន | ដៅសេថ[26]ចាំទុក |
| បណ្ដាំបិតា ។ | | |
| ៤៦- ត្រង់លក់ត្រង់ទិញ | ឲ្យរៀនចេះដឹង | ក្មេកជញ្ជីងណា |
| ឲ្យស្គាល់ស្រាលធ្ងន់ | ពីរទ្ធក្មែកវា | ឲ្យជៀងជាក់ជា |
| កត់កបសេចក្ដី ។ | | |
| ៤៧- រៀនគិតរៀនគ្នេរ | ទាត់ក្បាច់ឲ្យថៃ | រៀនគិតឲ្យវៃ |
| ឲ្យស្គាល់ខាតគង់ | ដើមចុងនោះនៃ | កុំជឿទុនគេ |
| យកមកដាក់ផ្សារ ។ | | |
| ៤៨- បើគេទារធាប់ | វិលវិងក្រឡាប់ | ហើយគេមកទារ |
| លក់ពុំដាច់ឡើយ | ខាននៅអសារ | ដ្បិតគេនឹងអាល |
| វិលវឹងទៅស្រុក ។ | | |
| ៤៩- ពុំទាន់ឲ្យគេ | គេទារមិនល្ហែ | កូននឹងជាទុក្ខ |
| ដ្បិតតែទំនិញ | ជឿគេមកលក់ | គេទាររំអុក |
| ព្រួយចិត្តចិន្តា ។ | | |
| ៥០- ចាំពាក្យទៀរស្បាន់ | កូនកុំទៅកាន់ | ទុនគេឡើយណា |
| បើមានទុនឯង | នោះសមកូនភ្វា | ទំនិញឯងហើយ |

[26] « សេច » ទីនេះ មានន័យថា « សេចក្ដី រាក់ជ្រៅនៃពាក្យប្រៀនប្រដៅរបស់ឪពុក ឱ្យដៅចាំទុកក្នុងចិត្ត។»

| | |
|---|---|
| ទៅពពាយនាយលក់ ។ | |
| នេះបទពំនោល : | |
| ៥១- ថោកថ្លៃដោយល្អអាក្រក់ | សារពើកុយក្អក |
| ផ្ទុកហើយប្រយ័ត្នឲ្យមួន ។ | |
| ៥២- សារពើទំនិញទន់រុន | ថ្លឹងហើយមើលគន់ |
| មើលភ្នែកជញ្ជីងឲ្យស្ទាត់ ។ | |
| ៥៣-ប្រយ័ត្នក្រែងគេបំបាត់ | មើលឲ្យប្រាកដ |
| កំណត់នៃភ្នែកជញ្ជីង ។ | |
| ៥៤- សំឡឹងគន់គយគិតក្រែង | កាន់គេកាន់ឯង |
| ឲ្យត្រង់កុំឲ្យខ្វាត់ខ្វះ ។ | |
| ៥៥- ដាក់ថ្លៃនោះឲ្យស្រឡះ | កុំឲ្យខាតខ្វះ |
| សះឥតមន្ទិលផងគ្នា ។ | |
| ៥៦- ទោះបីចាមចិនខ្មែរជ្វា | ផាត់ទាត់ឲ្យវា |
| កុំបីបង្វាតបង្វាន ។ | |
| ៥៧- លង់យូរហើយវានឹងមាន | ពាក្យពេចន៍ព្រួយប្រាណ |
| នឹងមានមន្ទិលសៅហ្មង ។ | |
| ៥៨- ទាស់ទែងពាក្យពេចន៍ផ្តាំផ្តួង | ឈ្លោះប្រកែកកង |
| ដ្បិតមានទៅមកៗ ។ | |
| ៥៩- តបដាល់លាន់ចៀរកែកកោក | ជេរពោលរំអុក |
| កុំចោលកង្វល់ផងគ្នា ។ | |
| ៦០- កូនអើយខ្មាស់គេតិចរា | ខ្មាស់រាស្ត្រប្រជា |
| មេបាសាច់ញាត់សាច់ផៅ ។ | |
| ៦១- ពាក្យទៀរទុកស្មើសំពៅ | តែងបើកក្តោងទៅ |
| លំនៅនគរទីស្ថាន ។ | |

| | |
|---|---|
| ៦២- កលមួយប្រដូចសំប៉ាន[27] | ច្រាសក្រដីងច្រាន( ?) |
| តែងនឹងចម្ងងទៅមក ។ | |
| ៦៣- ឱកូនខ្ញុំមខ្លួនពន្ធក | ដ្បិតទៀរមកយក |
| ប្រពន្ធកូនម្ដាយបាស្រុកខ្មែរ ។ | |
| ៦៤- កូនជួញបានទ្រព្យក្រាសក្រៃល | កូនយកបញ្ញើ |
| បណ្ដោះចន្ទោះផ្ញើទៅ ។ | |
| ៦៥- អស់សាច់សន្ដានញាតិផៅ | ដំបន់ទៀរនៅ |
| នគរស្រុកចិនឯនាយ ។ | |
| ៦៦- ខ្លួនទៀរចាស់ហើយនៅអាយ | ម្ដាយទៀរនៅនាយ |
| ក្រៃងមានជំងឿក្រីក្រ ។ | |
| ៦៧- ថាបើសំពៅទៅមក៏ | គេសួរដើរក៏ |
| ក្រៃងជួបនឹងសែ[28]នោះលាយ ។ | |
| ៦៨- បងប្អូនសាច់ញាតិពីឆ្ងាយ | គេចង់នៅអាយ |
| យកកូនរក្សាព្យាបាល ។ | |
| ៦៩- សារពើទំនិញផលក័ស្រ្ត | ចែកគ្នាធ្វើការ |
| ជួញប្រែដើមចង ។ | |
| ៧០- កុំកូនសំឡាញ់យូរលង់ | ដ្បិតមកនៅក្នុង |
| កំឡុងនគរស្រុកខ្មែរ ។ | |
| ៧១- ជួញបានប្រាក់មាសក្រាសក្រៃល | មកនៅស្រុកខ្មែរ |
| ចង់យកប្រពន្ធចុះចៅ ។ | |
| ៧២- ផ្សារមកជាអ្នកចិនចៅ | នោះទើបមកនៅ |

[27] ទូកមួយប្រភេទតដោយ ក្ដារ៥ ៥សន្ទឹកខាងក្បាលនិងកន្សៃរាង- ង។ វចនានុក្រមខ្មែរ ទំព័រ១៤២១។

[28] ឈ្មោះត្រកូល (គោត្តនាម)

| | |
|---|---|
| ពុំទាន់ចេះដឹងភាសា ។ | |
| ៧៣- ពុំទាន់ចេះដឹងម្ចូស្វា | ជះតែហុន[29]ណា |
| ដ្បិតវានៅជាចិនឆៅ ។ | |
| ៧៤- កូនអើយទៀរអ្នកប្រដៅ | ចាំច្បាប់ចិនឆៅ |
| ណាកូនពៅទៀរមាសថ្លៃ ។ | |
| ៧៥- ប្រែភាសាខ្មែរនៃ | កូនកើតនៅឯ |
| ដំបន់នគរស្រុកអាយ ។ | |
| ៧៦- មិនចេះស្រដីនិយាយ | ពាក្យចិនសម្មោទាយ( ?)[30] |
| ចេះតែភាសាពាក្យខ្មែរ ។ | |
| ៧៧- ទៀរនឹងប្រដៅចំណេះ( ?) | ប្រែជាពាក្យខ្មែរ |
| ឲ្យកូនបានដឹងណាចៅ ។ | |
| ៧៨- ទៀរប្រែពីច្បាប់ចិនឆៅ | ដ្បិតតែកូនចៅ |
| អម្ចាសសម្បត្តិកុងអួរ [31]។ | |
| ៧៩- ហេតុនោះទៀតអ្នករិះរក | យកច្បាប់ចិនមក |
| ប្រដៅប្រែជាច្បាប់ខ្មែរ ។ | |
| ៨០- ចាំច្បាប់នេះឲ្យស្ថិតស្ថេរ | យកទុកជាកេរ |
| ជាយសរបស់ទ្រព្យា ។ | |
| ៨១- ទុកស្មើសំពៅកេត្រា | ផ្ទុកអស់ទ្រព្យា |
| ទំធូរទំគួរ( ?)ធនធាន ។[32] | |
| ៨២- ខ្យល់មកស្ទាបក្តោងផាត់ប្រាន | ឆ្លងសាគរបាន |

[29] នំចិនផ្អែម

[30] ប្រហែលមកពីពាក្យសំស្ក្រឹត « សម្មោទន » គឺជា « សំដីពក់ទាក់ »

[31] កុង(ចិន) : ចាស់ព្រឹទ្ធាចារ្យ , ជីតា ;   អួរ(ចិន) :  អញ,   ខ្ញុំ  ។ « កុង អួរ »  គឺ ជីតារបស់អញ ខ្ញុំ។

[32] ធូ(ចិន) : ធំ ;    គុយ : ថ្លៃ, ដែលមានតម្លៃ

| | |
|---|---|
| *តល់ស្ថានលំនៅនាយណា ។* | |
| *៨៣- ពាក្យទៀរសេចគ្រេចវាចា* | *ចាំច្បាប់នេះណា* |
| *អ្នកមាសអ្នកកុំភ្លេចឡើយ ។* | |
| *៨៤- អស់ពាក្យទៀវឯងហើយ* | *ចូរស្ងួនត្រាណត្រើយ* |
| *នេះជាសូរេចម៉្ងៃះហោង ។* | |
| *៨៥- រីពាក្យខ្មៅចខ្មីនេះហោង* | *អស់កូនចិនផង* |
| *បានមើលអស់ច្បាប់នេះណា ។* | |
| *៨៦- កុំភ្លេចគុណគ្រូថ្លៃថ្លា* | *ទុកស្មើកេត្រា* |
| *ធ្ងាស់ធ្ងន់ធំក្រៃ ។* | |
| *៨៧- បានចេះបានដឹងហើយនៃ* | *ច្បាប់នេះថ្លាថ្លៃ* |
| *ជាចិនឲ្យគិតឲ្យថៃ ។* | |
| *៨៨- ច្បាប់នេះពាក្យចិនលាយខ្មែរ* | *ទៀរអ្នកបកប្រែ* |
| *សូរេចចែងចប់ម៉្ងៃះហោង ។ »* | |

*នេះសត្រាច្បាប់ចិន ។ ច្បាប់ចិន ។*[33]

[33] *ពុទ្ធសាសនាបណ្ឌិត្យ បានបោះផ្សាយ នាឆ្នាំ ១៩៥៨ មាន៣៣ទំព័រដាក់ ចំណងជើងថា ៖* **ល្បើកប្រដៅកូនចៅចិន** *និពន្ធ ដោយ អ៊ឹងខេង រស់នៅស្រុកស្មោង ខេត្តកំពង់ធំ ដែលជាសាច់ញាតិជីតាខ្ញុំ ខាងម្តាយ ។ ប្រសិនបើចង់ដឹង ពី ឥទ្ធិពល អក្សរសិល្ប៍ចិន នៅកម្ពុជា សូមអានអត្ថបទ សាស្ត្រាបណ្ឌិត ឃីងហុកឌី* **រស្មីកម្មអក្សរសិល្ប៍ចិន លើ កម្ពុជា នាសតវត្ស ទី ១៩ និង ទី ២០** *ភ្នំពេញ បណ្ណាគារអង្គរ ២០០៨ ១៦៦ទំព័រ ។*

ឯកសារខាងលើនេះចម្លងចេញពីសត្រាស្លឹករឹតតែសរសេរតាមអក្ខរាវិរុទ្ធវចនានុក្រមពុទ្ធសាសនបណ្ឌិត្យ ហើយសត្រានេះតម្កល់រក្សាទុកនៅបណ្ណាល័យសាលាបារាំងចុងបូព៌ាក្រុងប៉ារីសចុះលេខ២៤០គឺជាសត្រាស្លឹករឹតមានទាំងអស់ ១០ សន្លឹក គឺមានសន្លឹកចំណងជើងបូក៣សន្លឹកឥតមានចារអក្សរនិង៥សន្លឹកដែលមានចំណារ ទាំងពីរខាង តែសន្លឹកទី៦ជាសន្លឹកបញ្ចប់មានចារតែមួយខាង។ សត្រានេះ

តាក់តែង ជា កំណាព្យបទកាកគតិនិងពំនោល។ សន្លឹកនិមួយៗ មាន ទំហំ ៥៥៥X៥០mm និង មានចំណារ ៥បន្ទាត់ ហើយសន្លឹកចុងក្រោយ មានចំណារ តែ៣ បន្ទាត់ជាបញ្ចប់។ ខាងក្រោមនេះជារូប ថតសត្រា ៖









### សេចក្តីសង្កេតខ្លះៗលើសត្រាច្បប់ចិនៈ

តួព្យញ្ជន : **ក** និង ព្យញ្ជន : **ត** មានរូបរាងប្រហាក់ប្រហែល គ្នា។

តួព្យញ្ជន : **ជ** និង ព្យញ្ជន : **ជ** មានរូបរាងប្រហាក់ប្រហែលគ្នាដែរ។

ព្យញ្ជន : **យ**, **ស** ត្រូឡប់សរសេរទៅជាព្យញ្ជន : ផ្ញើជើងវិញ ។ តែមានជាខ្យល់សូរប្រកប ឧទាហរណ៍ **ហើ្យ** = **ហើយ**, **មួ្យ**=**មួយ**, **អ្ស**=**អស់**។ល។

ព្យញ្ជន : **ត** នៅប្រើនៅឡើយដូចនិង ព្យញ្ជន : ខ្យល់ព្យញ្ជន : **ដ**។ល។

ស្រះ **◌ោវ** គឺប្រើដូច ស្រះ **◌ៅ** សព្វថ្ងៃ។

ស្រះពេញតួ ប្រើធម្មតាជាទូទៅ ឧទាហរណ៍៖ **ឪវ** = **អាវ**, **រំឱក** = **រំអុក**, **ឱ្យ** ឬ **ឲ្យ** = **ឱយ** ឬ **អោយ** បច្ចុប្បន្ន។ល។